# ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ
**KINGDOM OF CAMBODIA**
**Nation - Religion - King**

ក្រសួងពាណិជ្ជកម្ម
*Ministry of Commerce*
លេខ ១២៣ ព.ណ.ករ

ភ្នំពេញ, ថ្ងៃទី ២៧ ខែ ១០ ឆ្នាំ ២០១៤

## សេចក្តីណែនាំ
## ស្តីពីការដាក់ពាក្យសុំចុះបញ្ជីម៉ាក ពាណិជ្ជនាម ការសុំប្តូរអាសយដ្ឋានរៀបចំនៃម្ចាស់ម៉ាក ការបញ្ជាក់ឡើងវិញនូវការប្រើប្រាស់ ឬមិនប្រើប្រាស់ម៉ាក

## ទេសរដ្ឋមន្ត្រី
## រដ្ឋមន្ត្រីក្រសួងពាណិជ្ជកម្ម

- បានឃើញរដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៩១៣/៩០៣ ចុះថ្ងៃទី ២៤ ខែ កញ្ញា ឆ្នាំ ២០១៣ ស្តីពីការតែងតាំងរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ ០២/នស/៩៤ ចុះថ្ងៃទី ២០ ខែ កក្កដា ឆ្នាំ ១៩៩៤ ដែលប្រកាសឲ្យប្រើប្រាស់ច្បាប់ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រមលេខ នស/រកម/០១៩៦/១៦ ចុះថ្ងៃទី ២៤ ខែ មករា ឆ្នាំ ១៩៩៦ ដែលប្រកាសឲ្យប្រើច្បាប់ស្តីពីការបង្កើតក្រសួងពាណិជ្ជកម្ម
- បានឃើញព្រះរាជក្រមលេខ នស/រកម/០២០២/០០៦ ចុះថ្ងៃទី ០៧ ខែ កុម្ភៈ ឆ្នាំ ២០០២ ដែលប្រកាសឲ្យប្រើច្បាប់ស្តីពីម៉ាក ពាណិជ្ជនាម និងអំពីការប្រកួតប្រជែងមិនស្មោះត្រង់
- បានឃើញអនុក្រឹត្យលេខ ១៣១ អនក្រ.បក ចុះថ្ងៃទី ១៩ ខែ មីនា ឆ្នាំ ២០១៤ ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅរបស់ក្រសួងពាណិជ្ជកម្ម
- បានឃើញអនុក្រឹត្យលេខ ៦៤ អនក្រ.បក ចុះថ្ងៃទី ១២ ខែ កក្កដា ឆ្នាំ ២០០៦ ស្តីពីការអនុវត្តច្បាប់ស្តីពីម៉ាក ពាណិជ្ជនាម និងអំពីការប្រកួតប្រជែងមិនស្មោះត្រង់
- យោងតាមការចាំបាច់របស់ក្រសួងពាណិជ្ជកម្ម។

## សម្រេច

**ប្រការ ១.-**

បានសម្រេចឲ្យការដាក់ពាក្យសុំចុះបញ្ជីម៉ាក ពាណិជ្ជនាម ការសុំប្តូរអាសយដ្ឋាននៃម្ចាស់ម៉ាក និងការបញ្ជាក់ឡើងវិញនូវការប្រើប្រាស់ ឬមិនប្រើប្រាស់ម៉ាក ត្រូវធ្វើឡើងនៅក្រសួងពាណិជ្ជកម្ម (នាយកដ្ឋាន

កម្មសិទ្ធិបញ្ញា) ដោយពុំចាំបាច់ឆ្លងកាត់តំណាងជាភ្នាក់ងារឡើយ ចំពោះអ្នកស្នើសុំទាំងឡាយណាដែលមានអាស័យដ្ឋាននៅព្រះរាជាណាចក្រកម្ពុជា។

**ប្រការ ២.-**

ចំពោះអ្នកស្នើសុំដែលមានលំនៅដ្ឋានអចិន្ត្រៃយ៍ ឬទីតាំងប្រកបអាជីវកម្មសំខាន់របស់ខ្លួនស្ថិតនៅក្រៅព្រះរាជាណាចក្រកម្ពុជា អាចមានសិទ្ធិជ្រើសរើសតំណាងជាភ្នាក់ងារណាមួយក៏បាន ឲ្យតែភ្នាក់ងារតំណាងនោះមានទីលំនៅ និងកំពុងប្រកបវិជ្ជាជីវៈនៅព្រះរាជាណាចក្រកម្ពុជា ឲ្យដាក់ពាក្យស្នើសុំជំនួស។ លក្ខណៈសម្បត្តិរបស់តំណាងជាភ្នាក់ងារ មានចែងលំអិតនៅក្នុងប្រកាសលេខ០៤៥ MOC/SM ២០១១ ចុះថ្ងៃទី ០៩ ខែ កុម្ភៈ ឆ្នាំ ២០១១ របស់ក្រសួងពាណិជ្ជកម្ម ស្តីពីភ្នាក់ងារតំណាងស្របច្បាប់នៃម្ចាស់ម៉ាកក្នុងព្រះរាជាណាចក្រកម្ពុជា។

**ប្រការ ៣.-**

មន្ត្រី ឬជនណាដែលរើសអើង បានជំរិត ឬបានទទួលនូវរបស់ ឬប្រាក់ ដោយប្រើប្រាស់អំណាចនៃមុខងាររបស់ខ្លួន មន្ត្រីឬជននោះ ត្រូវបានចាត់ទុកថាបានប្រព្រឹត្តិបទល្មើស ហើយនឹងត្រូវបានផ្តន្ទាទោសតាមច្បាប់ជាធរមាន។

**ប្រការ ៤.-**

ព័តមាននានា ទាក់ទងនឹងការលំបាក ដែលបង្កឡើងដោយមន្ត្រីទទួលពាក្យស្នើសុំចុះបញ្ជី អាចជូនដំណឹងមក រដ្ឋមន្ត្រីក្រសួងពាណិជ្ជកម្ម តាមរយៈ អគ្គាធិការ អគ្គនាយកសេវាពាណិជ្ជកម្ម ឬនាយកខុទ្ទកាល័យរដ្ឋមន្ត្រីក្រសួងពាណិជ្ជកម្ម ដែលមានទូរស័ព្ទលេខៈ ០១៦៨៥៥៥៨៩ ០១២៩៩២០៣៥ និង ០១២៨៦៨៣៥៨ ។

**ប្រការ ៥.-**

ប្រកាសទាំងឡាយណា ដែលមានខ្លឹមសារផ្ទុយនឹងប្រកាសនេះ ត្រូវចាត់ទុកជានិរាករណ៍។

**ប្រការ ៦.-**

នាយកខុទ្ទកាល័យ អគ្គនាយក អគ្គាធិការ ប្រធានគ្រប់អង្គភាពក្រោមឱវាទក្រសួង ត្រូវអនុវត្តប្រកាសនេះ ចាប់ពីថ្ងៃចុះហត្ថលេខាតទៅ ។

**ទេសរដ្ឋមន្ត្រី**

**រដ្ឋមន្ត្រីក្រសួងពាណិជ្ជកម្ម**

**ស៊ុន ចាន់ថុល**

<u>ចម្លងជូន៖</u>

-ទីស្តីការគណៈរដ្ឋមន្ត្រី
-ខុទ្ទកាល័យ **សម្តេចតេជោនាយករដ្ឋមន្ត្រី**
-ក្រសួង-ស្ថាប័នពាក់ព័ន្ធ
-អង្គភាពប្រឆាំងអំពើពុករលួយ
-គ្រប់សាលារាជធានី-ខេត្ត
-សភាពាណិជ្ជកម្មកម្ពុជា
-សមាគមរោងចក្រកាត់ដេរសម្លៀកបំពាក់កម្ពុជា
-ឯកសារ-កាលប្បវត្តិ